ក្រសួងអប់រំ យុវជន និងកីឡា
មន្ទីរអប់រំ យុវជន និងកីឡាខេត្តព្រះវិហារ
លេខ:..........✓..........អយកខ.

# សេចក្តីជូនដំណឹង
## ស្តីពី
## ការផ្អាកដំណើរការបង្រៀន និងរៀនជាបណ្តោះអាសន្នសម្រាប់ គ្រឹះស្ថានសិក្សាតាមបណ្តោយព្រំដែនកម្ពុជា-ថៃក្នុងស្រុកជាំក្សាន្ត ខេត្តព្រះវិហារ

យោង៖ -សភាពការណ៍តាមបណ្តោយព្រំដែនកម្ពុជា ថៃ

-អនុសាសន៍ណែនាំ របស់ឯកឧត្តមអភិបាល នៃគណៈអភិបាលខេត្តព្រះវិហារ

-អនុសាសន៍ណែនាំរបស់ឯកឧត្តមបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា។

មន្ទីរអប់រំ យុវជន និងកីឡាខេត្តព្រះវិហារ សូមជម្រាបជូនដល់គណៈគ្រប់គ្រងគ្រឹះស្ថានសិក្សា លោកគ្រូ អ្នកគ្រូ បុគ្គលិកអប់រំ អាណាព្យាបាល និងសិស្សានុសិស្សទាំងអស់ជ្រាបថា ដើម្បីជានាសុខសុវត្ថិភាពដល់លោកគ្រូ អ្នកគ្រូ បុគ្គលិកអប់រំ និងសិស្សានុសិស្សទាំងអស់ បញ្ចៀសបាននូវគ្រោះថ្នាក់ដែលបណ្តាលមកពីការបាញ់ផ្លោងកាំភ្លើងធំ តូចរបស់ភាគីថៃ ក្នុងអំឡុងពេលមានការឈ្លានពានមកលើព្រំដែនដីនៃព្រះរាជាណាចក្រកម្ពុជា ក៏ដូចជាក្នុងភូមិសាស្ត្រស្រុកជាំក្សាន្ត ខេត្តព្រះវិហារ។ មន្ទីរអប់រំ យុវជន និងកីឡាខេត្តព្រះវិហារ សម្រេចអនុញ្ញាតឱ្យគ្រឹះស្ថានសិក្សាទាំងអស់ដែលស្ថិតនៅជាប់តាមបណ្តោយព្រំដែនកម្ពុជា ថៃ ក្នុងស្រុកជាំក្សាន្តនៃខេត្តព្រះវិហារ ផ្អាកដំណើរការបង្រៀន និងរៀនជាបណ្តោះ អាសន្ន ចាប់ពីវេលាម៉ោង ០៧:០០ នាទីព្រឹក ថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០២៥ នេះរហូតដល់មានការជូនដំណឹងជាថ្មី ។

សេចក្តីដូចបានជម្រាបជូនដំណឹងខាងលើ សូមគណៈគ្រប់គ្រងគ្រប់គ្រឹះស្ថានសិក្សា លោកគ្រូ អ្នកគ្រូ បុគ្គលិកអប់រំ អាណាព្យាបាល និងសិស្សានុសិស្សទាំងអស់ជ្រាបជាព័ត៌មាន និងអនុវត្តប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់។

ថ្ងៃអង្គារ ៤រោច ខែមិគសិរ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
ព្រះវិហារ ថ្ងៃទី៩ ខែធ្នូ ឆ្នាំ២០២៥

ចម្លងជូន
-រដ្ឋបាលខេត្តព្រះវិហារ «ដើម្បីគោរពជូនជ្រាប»
-រដ្ឋបាលស្រុកជាំក្សាន្ត
-ការិ.អយក.នៃរដ្ឋបាលស្រុកជាំក្សាន្ត
-កាលប្បវត្តិ ឯកសារ-របប